# សង្កាត់សាលារៀនអូកឡិនដ៍

1000 Broadway, Suite 300
Oakland, CA 94607-4033

## សេចក្តីជូនដំណឹងអំពីសវនាការសាធារណៈ

**ទាក់ទងនឹងការពិនិត្យឡើងវិញជាចុងក្រោយ និងការអនុម័តផែនការសេវាកម្មប្រចាំឆ្នាំ និងផែនការថវិការប្រចាំឆ្នាំនៃតំបន់រៀបចំគម្រោងមូលដ្ឋានសម្រាប់កម្មវិធីអប់រំពិសេស (SELPA) ដែលបានដាក់ស្នើសុំសំរាប់ឆ្នាំសិក្សា 2021-2022 ។**

**ជូនចំពោះភាគីពាក់ពាន់ទាំងអស់៖**

**សូមកត់ចំណាំទុក** ថានៅថ្ងៃពុធ ទី 9 ខែមិថុនា ឆ្នាំ 2021 នៅម៉ោង 8:30 យប់ ឬនៅពេលក្រោយហ្នឹងបន្តិចក្នុងថ្ងៃហ្នឹង តាមរយៈអ៊ិនធឺណិត (ការឡាយតាមអ៊ិនធឺណិត និងទូរទស្ស KDOL ប៉ុស្តិ៍លេខ 27 (Comcast) និងប៉ុស្តិ៍លេខ 99 (AT&T)) នោះ ក្រុមប្រឹក្សាភិបាលនៃសង្កាត់សាលារៀនអូកឡិនដ៍ តាមកិច្ចប្រជុំធម្មតារបស់ខ្លួន នឹងបើកសវនាការជាសាធារណៈមួយ ស្តីអំពីផែនការសេវាកម្មប្រចាំឆ្នាំ និងផែនការថវិការប្រចាំឆ្នាំនៃតំបន់រៀបចំគម្រោងមូលដ្ឋានសម្រាប់កម្មវិធីអប់រំពិសេស (SELPA) ដែលបានដាក់ស្នើសុំសំរាប់ឆ្នាំសិក្សា 2021-2022។ ក្រុមប្រឹក្សាភិបាលនៅចុងបញ្ចប់នៃសវនាការអាចអនុម័តផែនការនានា។

គោលបំណងនៃសវនាការសាធារណៈនេះ គឺដើម្បីប្រមូលមតិយោបល់ពីសាធារណជនអំពីផែនការនានា និងដើម្បីធ្វើការកែសម្រួលដល់ផ្នែកណាមួយនៃឯកសារនេះ ប្រសិនបើត្រូវការចាំបាច់។

ឯកសារថតចម្លងមួយច្បាប់អំពីផែនការនានា គឺមានដាក់ជូនសម្រាប់ការពិនិត្យមើលជាសាធារណៈ ដោយសារតែបំរាមមិនឱ្យចេញក្រៅផ្ទះក្នុងពេលមានការរាតត្បាតដោយមេរោគកូវីដ-19 ដែលបានធ្វើឡើងដោយមន្ត្រីសុខភាពសាធារណៈប្រចាំខោនធីអាឡាមីដា ចាប់ផ្តើមនៅថ្ងៃទី 28 ខែឧសភា ឆ្នាំ 2021 នៅគេហទំព័រ http://www.ousd.us/domain/69។

s/ Kyla Johnson-Trammell
លេខាធិការ, ក្រុមប្រឹក្សាភិបាលនៃ
សង្កាត់សាលារៀនអូកឡិនដ៍